តើខ្ញុំនឹងដឹងចំនួនសរុបក្នុងគណនីរបស់ខ្ញុំយ៉ាងរយៈបណា?

មធ្យោបាយយ៉ាងងាយបំផុតដើម្បីដឹងអំពីចំនួនសរុបក្នុងគណនីរបស់អ្នកគឺអ្នកត្រូវ ទុកបង្ការទំនៃរបស់អ្នកទាំងអស់ ។ បើសិនជា អ្នកគ្មានបង្ការទំនៃទេ អ្នកអាចរំឭក ឃើលចំនួនសរុបរបស់អ្នកតាមអ៊ីនធើណេតនៅ www.ebtaccount.jpmorgan.com ឬអ្នកអាចទូរស័ព្ទទៅផ្នែកសេវាបំរើភ្ញៀវ ។ អ្នកអាចដឹងជានិច្ចនូវចំនួនសរុបក្នុងគណនីរបស់អ្នកមុនទីងអ្នកទៅទិញអ៊ីវ៉ាន់ ។

តើមានអ្វីកើតឡើង បើសិនជាម៉ាស៊ីន POS មិនដើរ?

បើសិនជាអ្នកចង់ទិញមុខម្ហូបអាហារដែលត្រឹមត្រូវតម្លៃមួយទីងជំនួយរបស់អ្នក ហើយម៉ាស៊ីន POS មិនដើរ ឬគ្មានម៉ាស៊ីនទោះ នៅទីងហាងលក់ដូរ អ្នកលក់ទីង ចំពេញត្រដាសមួយសន្លឹកហៅថាប័ណ្ណចំណាយ ។ អ្នកលក់ទីងចុះលេខប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់អ្នក ហើយទីងចំនួយទឹកប្រាក់ដែលអ្នកចំណាយ ។ មិនត្រូវឲ្យលេខ PIN របស់អ្នកទៅអ្នកគិតប្រាក់ទេ ។ អ្នកគិតប្រាក់ទីងទូរស័ព្ទសួរថាអ្នក មានប្រាក់ជំនួយម្ហូបអាហារ (តែប៉ុណ្ណោះ) គ្រប់នៅក្នុងគណនីរបស់អ្នកដើម្បីទិញម្ហូបអា ហារឬទេ ។ បើសិនជាមានប្រាក់ជំនួយម្ហូបអាហារគ្រប់នៅក្នុងគណនីរបស់អ្នក អ្នកទីង ត្រូវបានគេសុំឲ្យចុះហត្ថលេខានៅលើប័ណ្ណចំណាយ ហើយទីងផ្តល់ជូនក្រដាសចម្លងប័ណ្ណ ចំណាយនោះមួយសម្រាប់ ។ គឺមានសារៈសំខាន់ណាស់ក្នុងការរក្សាទុកក្រដាសចម្លងនេះ ដើម្បីអ្នកអាចដកទូរវិចនួន ដែលអ្នកបានចំណាយចេញពីចំនួនសរុបចេញបង្ការទំនៃ EBT ចុងក្រោយរបស់អ្នក ។ នេះគឺទីងបង្ហាញអ្នកពី ចំនួនសរុបពេលបច្ចុប្បន្ននៅក្នុងគណនី របស់អ្នក ។ ហាងលក់ដូរមិនអាចគិតចំនួនសរុបនៅក្នុងប័ណ្ណចំណាយនេះដោយដៃបានទេ ចំពោះជំនួយប្រាក់សុទ្ធ ។

តើខ្ញុំអាចទៅកន្ទ្ងេបេឡ្យាការនៅក្នុងធានាគារ ហើយដកប្រាក់ឬ ចង់ដឹងចំនួនក្នុងគណនី EBT របស់ខ្ញុំបានឬទេ?

ទេ, អ្នកអាចដកប្រាក់បានពីម៉ាស៊ីន ATM ឬតាមរយៈការដកឲ្យគេអាច/ឬដកពី ជំនួយប្រាក់សុទ្ធតែប៉ុណ្ណោះពីហាងលក់ដូរដែល សហការតែប៉ុណ្ណោះ ។ បើសិនជា អ្នកមានសំនួរនានា ចូរទូរស័ព្ទទៅផ្នែកសេវាបំរើភ្ញៀវ ឬសួរអ្នកធ្វើការផ្នែកសងមកិច្ចរបស់ អ្នក ។

បើសិនជាអ្នកមានតិចជាង $10.00 នៃជំនួយប្រាក់នៅក្នុងប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់ខ្ញុំ តើខ្ញុំនឹងដកប្រាក់ចេញ យ៉ាងណា?

អ្នកអាចប្រើទិញរបស់ណារ ឬដកប្រាក់នៅហាងលក់ដូរដែលសហការដើម្បីយកប្រាក់នេះ ។

តើមានមានថ្ងៃឈ្នួលឬម្ងៃថ្ងៃមុនពីលើឬសំរាប់ការប្រើប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់ខ្ញុំ?

គឺគ្មានថ្ងៃឈ្នួលដាច់ខាតសំរាប់ការប្រើជំនួយម្ហូបអាហារ ដើម្បីទិញម្ហូបអាហារ ជាមួយនឹងប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោន របស់អ្នក ។ ហើយក៏គ្មានឈ្នួលដាច់ខាត សំរាប់ការប្រើជំនួយប្រាក់សុទ្ធដើម្បីទិញម្ហូបអាហារឬដកប្រាក់ពីម៉ាស៊ីន POS ។ នៅតាម ម៉ាស៊ីន ATM ឈ្នួលដកប្រាក់ម្តង 85 សេន គឺការត់ចេញពីគណនី ប្រាក់សុទ្ធរបស់អ្នក ដោយស្វ័យប្រវត្តិរាល់ពេលអ្នកដកប្រាក់ ។

ថ្ងៃថ្មមពីលើគឺជាឈ្នួលបន្ថែម ដែលបានទារយកដោយម្ចាស់ម៉ាស៊ីន ATM ឬ POS សំរាប់ការប្រើម៉ាស៊ីនដើម្បីដកប្រាក់ ។ ថ្ងៃថ្ងៃមពីលើ បើសិនជាមានសំរាប់ការ ដកប្រាក់ក็ទីងកាត់យកដោយស្វ័យប្រវត្តិចេញពីគណនីរបស់អ្នក ។ បើសិនជាអ្នកមិន ចង់ចង់ថ្ងៃថ្ងៃមពីលើទេ ធម្មតាគឺគ្រាន់តែលុបការប្រើប្រាស់ប័ណ្ណនោះ ហើយអញ្ជើញ ទៅកន្ទ្ងមម៉ាស៊ីន ATM ឬ POS ផ្សេងមួយទ្យេតដែលមិនទារថ្ងៃថ្ងៃមពីលើ ។

តើមានលក្ខខ័ណ្ឌយ៉ាងណា ចំពោះប្រយ៉ងប្រើប្រាស់ប័ណ្ណជំនួយប្រាក់សុទ្ធ EBT របស់ខ្ញុំ ។

គឺជាការផ្ទុយនឹងច្បាប់ផ្លូវច្បាប់ក្នុងការប្រើប័ណ្ណ EBT ឬដកប្រាក់ពីប័ណ្ណ EBT ដើម្បីលេខវ៉ែ្ឍង ។ ការលេងវ៉ែ្ឍងមានរួមទាំង ទិញឆ្នោត, គុបាញ់ឃ្ញ, បុកប៊ីយ៉ា, ប៊ីងរត្រា, ប្រណាំងសេះ, វ៉ែ្ឍងកាស៊ីណូនឹងវ៉ែ្ឍងស៊ីសងដទៃទ្យេត។

មានអ្វីកើតឡើង បើសិនជាខ្ញុំមិនប្រើប្រាក់ជំនួយរបស់ខ្ញុំ?

បើសិនជាអ្នកមិនប្រើយ៉ាងហោចណាស់តែបន្តិចបន្តួចពីជំនួយរបស់អ្នកនៅក្នុងរយៈពេល 365 ថ្ងៃជំនួយនោះនឹងត្រូវបានគេលុបចោល។ ក្នុងករណីខ្ះជំនួយទាំងនេះនឹងមិន អាចជំនួសបានទេ ។

តើខ្ញុំអាចដាក់ប្រាក់ទៅក្នុងគណនី EBT របស់ខ្ញុំបានឬទេ?

ទេ ។ អ្នកអាចដកប្រាក់ចេញបានតែប៉ុណ្ណោះពីគណនីប្រាក់របស់អ្នក ។

តើដាក់ប្រាក់ក្នុងគណនីយដោយផ្ទាល់ដារ៉ូ?

ក្រៅពីការប្រើ EBT, អ្នកអាចជ្រើសយកការដាក់ប្រាក់ជំនួយសុទ្ធដារ៉ូងរាល់ខែដោយផ្ទា ល់ទៅក្នុងគណនីធានាគារផ្ទាល់ខ្លួនថ្មី ឬធានាគារផ្ទាល់ខ្លួនពេលបច្ចុប្បន្ន ។ អ្នកមិនអាចដាក់ ដោយផ្ទាល់បានទេសំរាប់ជំនួយផ្នែកម្ហូបអាហារ ។ ចូរទំាក់ទងទៅអ្នកធ្វើ ការផ្នែកសងមកិច្ច ដើម្បីទទួលពត៌មានជាច្រើនទ្យេត ឬទូរស័ព្ទតាមលេខមិនគិតថ្ងៃលេខ 1-888-235-2954 ។

តើអ្នកកាន់ប័ណ្ណជំនួសដារ៉ូ ?

អ្នកអាចជ្រើសយកជនម្នាក់ ដែលហៅថាអ្នកកាន់ប័ណ្ណជំនួស ដើម្បីទទួលជំនួយរបស់អ្នក សំរាប់អ្នក ។ អ្នកកាន់ប័ណ្ណជំនួស ត្រូវតែទៅការិយាល័យនៅតាមតំបន់ ដើម្បីទទួលប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោន ហើយនឹងលេខ PIN ខ្លួនគេ ។ បើសិនជាអ្នកត្រូវការអ្នក កាន់ប័ណ្ណជំនួស ចូរជ្រើសយកជនម្នាក់ដែលអ្នកទុកចិត្ត ។ ចូរចាំដាក់ថា ជំនួយដែលបាត់ប ត្រូវគេលួចទីង មិនអាចចេញសងវិញបានទេ ។ អ្នកអាចលុបប័ណ្ណអ្នកកាន់ជំនួសដោយ ទូរស័ព្ទទៅផ្នែកបំរើភ្ញៀវ ។ សំរាប់ពត៌មានបន្ថែម ឬដើម្បីទទួលក្រដាសពាក្យការអនុញ្ញាត ចូរទូរស័ព្ទទៅការិយាល័យ DSHS តាមតំបន់របស់អ្នក ។

តើខ្ញុំទូរស័ព្ទផ្នែកសេវាបំរើភ្ញៀវនៅពេលណា?

- ទូរស័ព្ទ បើសិនជាកាតអ្នកបានបាត់ឬត្រូវគេលួចឬខូច ។
- ទូរស័ព្ទ បើសិនជាអ្នកភ្លេចឬបាត់លេខ PIN របស់អ្នក ។
- ទូរស័ព្ទ ដើម្បីដូរលេខ PIN របស់អ្នក ។
- ទូរស័ព្ទ ដើម្បីឲ្យដឹងពីចំនួនសរុបរបស់អ្នក ។
- ទូរស័ព្ទ ដើម្បីឲ្យដឹងពីការប្រើប័ណ្ណចំនួន 10 លើកចុងក្រោយ។
- ទូរស័ព្ទ ដើម្បីស្នើសុំប្រវត្តិនៃការប្រើប័ណ្ណពីរខែចុងក្រោយ។
- ទូរស័ព្ទ បើសិនជាអ្នកមានសំនួរឬត្រូវការជំនួយជាមួយប័ណ្ណរបស់អ្នក ។

តើយ៉ាងណា បើសិនជាខ្ញុំមានផែនការផ្លាស់កន្ទ្ងេងឬប្តូរអាសយដ្ឋានរបស់ខ្ញុំ?

អ្នកត្រូវតែទាក់ទងទៅអ្នកធ្វើការផ្នែកសង មកិច្ចរបស់អ្នក បើសិនជាអ្នកផ្លាស់កន្ទ្ងេងឬជួរ អាសយដ្ឋាន ។

This pamphlet is available in your language at your local DSHS Office.

ይህ አአተ መጽሔት በቋንቋዎ በአካባቢዎ የዲኤስኤችኤስ ጽህፈት ቤት ይገኛል። (Amharic)

إن هذه النسخة موفرة لك بلغتك في مكتب الـ DSHS في الضاحية التي تسكن بها. (Arabic)

ក្រដាសស្យេរភៅនេះមានផ្តល់ជូនជាភាសារលោកអ្នកនៅនឹងការិយាល័យ DSHS ប្រចាំតំបន់របស់លោកអ្នក ។ (Cambodian)

本小冊備有您的語言版本，可向您當地的 DSHS 辦事處索取。(Chinese)

این جزوه در زبان شما در اداره خدمات اجتماعي و درماني DSHS منطقه ايتان در دسترس مي باشد. (Farsi)

Dlaim ntawv nuav muaj txhais ua koj yaam lug hab nwg nyob rua ntawm lub DSHS kws ze koj ko. (Hmong)

이 팜플렛의 한국어 팜플렛은 귀하지역 관할 보건사회부(DSHS) 사무소에 비치돼 있습니다.(Korean)

ປື້ມຈຸ່ມນີ້ຫາວນີ້ມີເປັນພາສາຂອງທ່ານຢູ່ທີ່ຫ້ອງການ DSHS ຫ້ອງຖິ່ນຂອງທ່ານ. (Laotian)

ਇਹ ਪੈਂਫਲੇਟ ਤੁਹਾਨੂੰ ਮਿਲ ਸਕਦਾਂ ਹੈ ਆਪ ਦੀ ਭਾਸ਼ਾ ਵਿਚੱ ਆਪਣੇ ਸਥਾਨੀ DSHS ਦਫਤਰ ॥ (Punjabi)

Acest pamflet este disponibil în limba dumneavoastră la oficiul DSHS local. (Romanian)

Вы можете получить эту брошюру на своём языке в своём местном офисе DSHS.(Russian)

O lo'o maua le tusi lea i lau gagana i le ofisa o le Welfare (DSHS). (Samoan)

Ovaj pamflet je dostupan i na vašem jeziku u vašem mjesnom DSHS uredu. (Serbo-Croatian)

Waraaqahani waxaad ka helikartaa xafiiska Walfeerka, DSHS, ee kuu dhow, iyaga oo ku qorran afgaaga. (Somali)

Ang pamphlet na ito ay nakasulat rin sa Tagalog at makukuha sa tanggapan ng DSHS na pinakamalapit sa inyo. (Tagalog)

እዚ መጽሔት እዚ ብቓንቋኹም ኣብ ከባቢኹም ዝርከብ ቤት ጽሕፈት ዋልፈር ይርከብ (Tigrigna)

Ви можете одержати цю брошуру на своїй мові в своєму місцевому офісі DSHS.(Ukrainian)

Tập sơ liệu này hiện có bằng ngôn ngữ của quí vị tại văn phòng DSHS địa phương.(Vietnamese)

USDA គឺជាវិការសមភាពផ្លូវ
អ្នកផ្តល់ការបំរើនិងនិយោជក
©2005 JPMorgan Chase & Co. រក្សាសិទ្ធិគ្រប់យ៉ាង ។

Washington State Department of Social & Health Services
DSHS 22-310(X) CA (Rev. 4/05)

ប័ណ្ណ EBT Quest
រដ្ឋវ៉ាស៊ីនតោនរបស់អ្នក ។

ដើម្បីពត៌មាននៅក្នុងគ៉ាណនី, ចូរទៅមើល
www.ebtaccount.jpmorgan.com

ឬទូរស័ព្ទទៅ

សេវាបំរើភ្ញៀវ

1-888-328 -9271
(ទូរស័ព្ទបង់ប្រាក់មិនរាប់បញ្ជូលទេ)
711 (TTY State Relay)
1-800-833-6385 (Telebraille)

សូមស្វាគមន៍ចំពោះ ការផ្តល់ប្រាក់ជំនួយតាមអេឡិកត្រូនិចនៃរដ្ឋវ៉ាស៊ីនតោន **(EBT)** ហើយនិងប័ណ្ណ **EBT Quest** រដ្ឋវ៉ាស៊ីនតោន – ដ៏មានផ្សាយមួយមានសុវត្ថិភាព ត្រូវចិត្ត និងងាយស្រួលសំរាប់អ្នកប្រើក្នុងការទទួលជំនួយ ។

បើសិនជាអ្នកមានគុណសម្បត្តិទទួលជំនួយម្ហូបអាហារដ៏មូលដ្ឋាន អ្នកអាចប្រើប័ណ្ណ *EBT Quest* រដ្ឋវ៉ាស៊ីនតោនដើម្បី:
- ទិញមុខម្ហូបអាហារដែលបានជ្រើសរើសនៅហាងដែលទទួលយកប័ណ្ណអាហាររដ្ឋ

បើសិនជាអ្នកមានគុណសម្បត្តិទទួលជំនួយជាប្រាក់សុទ្ធ អ្នកអាចប្រើប័ណ្ណ *EBT Quest* រដ្ឋវ៉ាស៊ីនតោនដើម្បី:
- បើកប្រាក់ ឬបង់ថ្លៃទំនិញទិញនៅហាងដែលទទួលយកប័ណ្ណអាហាររដ្ឋ
- ដកប្រាក់ជំនួយរបស់អ្នកពីម៉ាស៊ីន ATM ទានា

គឺងាយស្រួលបំផុត!

របៀបប្រើប័ណ្ណ EBT QUEST រដ្ឋវ៉ាស៊ីនតោននៅតាមហាងជំនួយ

1. ត្រូវដឹងពីចំនួនប្រាក់ដែលមាននៅក្នុងប័ណ្ណរបស់អ្នកមុននឹងទៅទិញអ៊ីវ៉ាន់ទានា ។
2. អូសប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់អ្នកតាមចន្លោះចំណុចម៉ាស៊ីន Point-Of-Sale (POS) ឬ ឲ្យប័ណ្ណរបស់អ្នកទៅអ្នកលក់/អ្នកគិតប្រាក់ ។
3. ត្រូវឲ្យប្រាកដប្រាប់ទៅអ្នកលក់ថាតណានីណាមួយដែលត្រូវឲ្យគេដកយក (គណនីផ្នែកម្ហូបបឬផ្នែកប្រាក់សុទ្ធ)។
4. ចុចលេខសំងាត់ផ្ទាល់ខ្លួនខ្លួង់ (PIN) នៅខ្លួង់ចុចលេខ ។ ម៉ាស៊ីនទីងបង្ហាញសញ្ញាផ្កាយ **** ។
5. ចុចត្រង់ OK ឬត្រង់ផ្ទៃចុច ENTER ។
6. អ្នកលក់ចុចលេខចំនួនថ្លៃទំនិញទាំងអស់ ហើយបើសិនជាចំនួននោះត្រូវហើយចុចត្រង់ YES ។
7. អ្នកលក់ទីងឲ្យបង្ហាន់ដៃមកអ្នក; សូមឲ្យប្រាកដថាពត៌មាននៅក្នុងបង្ហាន់ដៃនោះគឺត្រឹមត្រូវ ។
8. រក្សាបង្ហាន់ដៃនេះទុក ដើម្បីអ្នកទីងដឹងថាចំនួនប្រាក់នៅសល់ថ្មីរបស់អ្នកសំរាប់យកទៅចាយទិញអ៊ីវ៉ាន់លើកក្រោយទៀត ។

របៀបប្រើអាចខុសៗគ្នាតាមរំបៃម៉ាស៊ីន POS និមួយៗដែលអ្នកប្រើ - សួរអ្នកលក់បើសិនជាអ្នកត្រូវការឲ្យជួយ ។

ចំនួនស្មើទីងតំរៃម្ហូបអាហារតែប៉ុណ្ណោះដែលទីងដកចេញពីតណានីជំនួយផ្នែកម្ហូបអាហាររបស់អ្នក ។ ហាងលក់ដូរ ទីងមិនអាចលុយឲ្យអ្នកទេពីជំនួយសំរាប់ទិញម្ហូបអាហារ ។

អ្នកអាចប្រើជំនួយសុទ្ធនេះហាងលក់ដូរដើម្បីដកប្រាក់ប៉ុណ្ណោះ ឬទិញម្ហូបអាហារទីងរបស់ របមិនមែនជាម្ហូបអាហារទាំងពីរមុខបាន (សាច, កន្ទបក្មេង ។ល។) ។ ហាងលក់ដូរក៏អាចដកប្រាក់សុទ្ធឲ្យអ្នកបាននៅពេលអ្នកទិញអ៊ីវ៉ាន់ដោយប្រើគណនីប្រាក់សុទ្ធរបស់អ្នក ។ បើសិនជាអ្នកមានសំនួរណាមួយ ចូរសួរទៅអ្នកលក់ ។

តើប្រើប័ណ្ណ EBT QUEST រដ្ឋវ៉ាស៊ីនតោនរបស់អ្នករបៀបណានៅតាមម៉ាស៊ីនដកប្រាក់ជាស្វ័យប្រវត្តិ (ATM)

(សំរាប់ដកតែប្រាក់ជំនួយសុទ្ធតែប៉ុណ្ណោះ ; ជំនួយម្ហូបអាហារ មិនអាចដកតាមម៉ាស៊ីន ATM បានទេ)

1. ស៊ីកចូលបូអូសប័ណ្ណរបស់អ្នក ។
2. ចុចលេខអត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នក (PIN) ហើយចុចត្រង់ OK ឬត្រង់ផ្ទៃចុច ENTER ។
3. ចុចត្រង់ខ្លួង់ដែលសរសេរ WITHDRAW CASH (ដកប្រាក់សុទ្ធ) រួចហើយចុចខ្លួង់ CHECKING (គណនីចាយ) ។
4. ចុចចំនួនដែលអ្នកចង់ដកជាចំនួនប្រាក់លេខគត់ (ឧទាហរណ៍ $20, $40, $60 ។ល។) ។
5. បើសិនជាមានការទារថ្លៃថែមពីលើចុចខ្លួង់ YES ដើម្បីយល់ព្រមហើយបន្តទៀត ។
6. យកប័ណ្ណរបស់អ្នក, បង្ហាន់ដៃរបស់អ្នកនិងប្រាក់របស់អ្នក ។
7. រាប់ប្រាក់របស់អ្នក ហើយប្រៀបធៀបវារទៅនឹងបង្ហាន់ដៃរបស់អ្នក ។
8. រក្សាបង្ហាន់ដៃរបស់អ្នកទុកដើម្បីជួយអ្នកតាមដាន ចំនួននៅសល់របស់អ្នកសំរាប់ការដកប្រាក់លើកក្រោយទៀត ។

អ្នកប្រហែលត្រូវប្រើម៉ាស៊ីនច្រើនដងដើម្បីដកប្រាក់ទាំងអស់ពីប្រាក់ជំនួយសុទ្ធពីម៉ាស៊ីន ATM បើសិនជា ម៉ាស៊ីនមានការកំរិត ចំនួនប្រាក់ដែលអ្នកអាចដកមួយលើក។ ។ វាទីងមានឈ្មួល 85 សេនសំរាប់ការដកប្រាក់ពីម៉ាស៊ីនម្តង។ ដែលទីងដកចេញដោយស្វ័យប្រវត្តិពីចំនួនប្រាក់ក្នុងគណនីរបស់អ្នកដាការទារថ្លៃថែមពីលើរបស់ធានាគារ ។

បើសិនជាម៉ាស៊ីន ATM ស្រួចទុកប័ណ្ណរបស់អ្នក ចូរទាក់ទងទៅផ្នែកបំរើអតិថិជនឬអញ្ជើញទៅការិយាល័យ DSHS ក្នុងតំបន់របស់អ្នកសំរាប់ទទួលប័ណ្ណជំនួសឡើងវិញ ។

សំនួរនិងចម្លើយអំពី EBT រដ្ឋវ៉ាស៊ីនតោន

តើខ្ញុំទទួលជំនួយរបស់ខ្ញុំជាមួយប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនយ៉ាងដូចម្តេច?

រៀងរាល់ខែ ជំនួយរបស់អ្នកទីងត្រូវដាក់បញ្ចូលទៅក្នុងគណនីរបស់អ្នកដោយស្វ័យប្រវត្តិ ។ អ្នកទីងប្រើប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនដដែលនោះជារៀងរាល់ខែដើម្បីដកជំនួយរបស់អ្នក ។ ដោយសារតែអ្នកប្រើប័ណ្ណជំនួយរបស់អ្នកសំរាប់ដកប្រាក់ ឬទិញរបស់របរ, ចំនួនសរុបនៃគណនីរបស់អ្នកទីងថយចុះ ។

នៅពេលណាខ្ញុំទទួលជំនួយរបស់ខ្ញុំ?

ជំនួយទីងដាក់បញ្ចូលទៅក្នុងគណនី EBT របស់អ្នកក្នុងថ្ងៃដដែលដារៀងរាល់ខែ ទោះបីជាថ្ងៃនោះជាថ្ងៃចុងអាទិត្យឬថ្ងៃឈប់សំរាក ក៏ដោយ ។ រកមើលលេខបួនខ្ទង់ចុងក្រោយនៃក្រុមជំនួយម្ហូបអាហារជាមូលដ្ឋាន (AU) របស់អ្នកនៅលើតារាងដូចខាងក្រោមនេះ ។ រួចហើយមើល តាមដូរទីងដើម្បីរកមើលថ្ងៃនៃខែដែលជំនួយម្ហូបអាហាររបស់អ្នកនឹងមាននៅក្នុងប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីន គោនរបស់អ្នក ។ ការចុះថ្ងៃនៃជំនួយម្ហូបអាហាររបស់អ្នកគឺក៏មានបោះពុម្ពនៅលើលិខិតជូនដំណឹងការយល់ព្រមផ្តល់ជំនួយផ្នែកម្ហូប អាហាររបស់អ្នក ។ ប្រាក់ជំនួយសុទ្ធនឹងអាចមាននៅថ្ងៃទីមួយដារៀងរាល់ខែ ។ ជំនួយទាំងអស់គឺអាចមាននៅម៉ោង 9:00 ព្រឹកម៉ោង ថាំស៊ីហ្គិក ។ ជំនួយណាមួយដែលសល់នៅចុងខែមុនទីងត្រូវដាក់បញ្ចូលទៅខែបន្ទាប់ទៀត ។

លេខចុងក្រោយ ID នៃជំនួយផ្នែកម្ហូបអាហារចប់ត្រង់លេខ	អ្នកនឹងទទួលជំនួយផ្នែកម្ហូបអាហាររបស់អ្នកនៅ
1	ថ្ងៃទី 1 នៃខែ
2	ថ្ងៃទី 2 នៃខែ
3	ថ្ងៃទី 3 នៃខែ
4	ថ្ងៃទី 4 នៃខែ
5	ថ្ងៃទី 5 នៃខែ
6	ថ្ងៃទី 6 នៃខែ
7	ថ្ងៃទី 7 នៃខែ
8	ថ្ងៃទី 8 នៃខែ
9	ថ្ងៃទី 9 នៃខែ
0	ថ្ងៃទី 10 នៃខែ

តើនៅទីណាខ្ញុំអាចប្រើប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីន គោនរបស់ខ្ញុំ?

អ្នកអាចប្រើប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់អ្នកនៅហាងលក់ដូរដែលបានចូលរួមហើយនិងម៉ាស៊ីន ATM (ម៉ាស៊ីនដក ប្រាក់សំរាប់តែជំនួយប្រាក់សុទ្ធតែប៉ុណ្ណោះ) ទូទាំងប្រទេស ។ អ្នកក៏អាចប្រើប័ណ្ណរបស់អ្នកនៅទីណាដែលអ្នកឃើញមានសញ្ញា Quest ។ បើសិនជាអ្នកមិនឃើញសញ្ញា Quest ទេចូរសួរទៅនាយកគ្រប់គ្រងការងារនៃហាងលក់ដូរ ថាតើអ្នកអាចប្រើប័ណ្ណនៅហាង លក់ដូរនេះដើម្បីទិញម្ហូបអាហារ ឬដកប្រាក់ជំនួយបានឬបានទេ ។

តើខ្ញុំគួរធ្វើដូចម្តេច បើសិនជាខ្ញុំបាត់ប័ណ្ណរបស់ខ្ញុំ?

បើសិនជាអ្នកបានបាត់, ត្រូវគេលួច, ឬខូចប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីនតោនរបស់អ្នក ហើយអ្នកត្រូវការប័ណ្ណជំនួសថ្មី ចូរទូរស័ព្ទទៅបណ្តាញឥតគិតថ្លៃផ្នែក សេវាបំរើអ្នកវរលេខ 1-888-328-9271 ឬអញ្ជើញ ទៅការិយាល័យ DSHS ក្នុងតំបន់របស់អ្នក ។

តើលេខប័ណ្ណរបស់ខ្ញុំមានប៉ុន្មាន?

លេខប័ណ្ណរបស់អ្នកគឺមាន 16 ខ្ទង់នៅខាងមុខប័ណ្ណរបស់អ្នក ។

ធ្វើដូចម្តេចបើសិនជាប័ណ្ណរបស់ខ្ញុំប្រើមិនកើត?

ទូរស័ព្ទទៅផ្នែកបំរើអ្នក្ស ហើយគេទីងជួយអ្នក ។ លេខទូរស័ព្ទនេះគឺមាននៅខាងក្នុងប័ណ្ណរបស់អ្នក ។ ផ្នែកសេវាបំរើអ្នកគ្រប់ចំរើ 24 ម៉ោងក្នុងមួយថ្ងៃ, 7 ថ្ងៃក្នុងមួយអាទិត្យ (មិនរាប់ចូលទូរស័ព្ទដែលចាក់កាក់ទេ) ។

តើធ្វើដូចម្តេច បើសិនជាមានការដកប្រាក់មិនត្រឹមត្រូវ ចេញពីគណនីរបស់ខ្ញុំ?

នៅពេលអ្នកលក់ត្រូវគេគិតថ្លៃលើសច្រើនពេកឬតិចពេញចេញពីគណនី EBT របស់អ្នក ដោយសារតែមានបញ្ហាក្នុងប្រព័ន្ធកុំព្យូទ័រ ការកែតំរូវអាចត្រូវធ្វើចំពោះតំរៃសរុបរបស់អ្នក ។ ការកែតំរូវនេះអាចមាន ការប៉ះពាល់ដល់ចំនួនសរុបប្រាក់ជំនួយខែតម្លៃរូវនេះ និងខែក្រោយរបស់អ្នក ។ អ្នកនឹងត្រូវគេផ្ញើក្រដាសជូនដំណឹងពីការកែតំរូវ EBT បើសិនជាមានការបន្ថយចំនួនសរុបរបស់អ្នក ។

តើខ្ញុំថែរក្សាប័ណ្ណរបស់ខ្ញុំរបៀបយ៉ាងណា?

1. ចុះហត្ថលេខានៅខាងខ្នង់ប័ណ្ណរបស់អ្នក ។
2. កុំសរសេរលេខ PIN របស់អ្នកនៅលើប័ណ្ណ ។
3. រក្សាប័ណ្ណរបស់អ្នកឲ្យមានសុវត្ថិភាពនិងស្អាតល្អ ។
4. ចូរកុំបត់ប័ណ្ណរបស់អ្នក ។
5. ទុកប័ណ្ណរបស់អ្នកឲ្យឆ្ងាយពីដែកឆក់នៃនិងគ្រឿងអេឡិកត្រូនិច ដូចជា TV, វិទ្យុ, VCR, ចង្ក្រាន មិក្រូវេវ, ។ល។
6. កុំដាក់ផ្ទាល់ក្រោមកំដៅថ្ងៃ (ឧ.ហ. ដាក់លើចាំណ្ណរថយន្តក្រោមកញ្ចក់មុខ) ។
7. កុំចោះប័ណ្ណរបស់អ្នកចោល, ប្រើប័ណ្ណដដែលតែមួយជារៀងរាល់ខែដរាបណាអ្នកនៅតែទទួលជំនួយ ។

តើអ្វីជាលេខអត្តសញ្ញាណផ្ទាល់ខ្លួន (PIN)?

លេខ PIN គឺជាលេខសម្ងាត់ជួនខ្ទង់ដែលអនុញ្ញាតឲ្យអ្នកប៉ុណ្ណោះ ដើម្បីប្រើប័ណ្ណ EBT Quest រដ្ឋវ៉ាស៊ីន គោនរបស់អ្នក ។ បើសិនជាអ្នកបានទទួលប័ណ្ណរបស់អ្នកតាមប៉ុស្តិ៍សំបុត្រ អ្នកត្រូវទទួរសំគ្ងទៅផ្នែកបំរើអ្នក្ស្ត្រវដើម្បីជ្រើសលេខ PIN ថ្មីឬលេខជំនួស ។ ដាច់ខាតមិនត្រូវប្រាប់លេខ PIN របស់អ្នកទៅអ្នកណាម្នាក់! បើសិនជាអ្នកណាម្នាក់ដឹងលេខ PIN របស់អ្នកគេអាចប្រើប័ណ្ណរបស់អ្នក ដើម្បីដកយកប្រាក់ជំនួយទាំងអស់ - ហើយប្រាក់ជំនួយនោះនឹងមិនអាចសងជំនួសឲ្យវិញបានទេ ។

តើយ៉ាងណា បើសិនជាខ្ញុំភ្លេចលេខ PIN របស់ខ្ញុំ ?

បើសិនជាអ្នកភ្លេចលេខ PIN របស់អ្នកឬចង់ផ្លូរលេខ PIN របស់អ្នក, អ្នកអាចទូរសំគ្ងទៅផ្នែកសេវាបំរើអ្នក្ស្ត្រវឬអញ្ជើញទៅ ការិយាល័យ DSHS ក្នុងតំបន់របស់អ្នកដើម្បីជ្រើសលេខ PIN ថ្មី ។ អ្នកគួរជ្រើសលេខបួនខ្ទង់ដែលងាយស្រួលសំរាប់អ្នកក្នុងការចងចាំ ប៉ុន្តែមានការពិបាកចំពោះជនដទៃដើម្បីតិតគ្ងរកលេខនោះ ។

តើយ៉ាងណាបើសិនជាខ្ញុំចុចលេខ PIN ខុស?

បើសិនជាអ្នកមានការពិបាកក្នុងការចងចាំលេខ PIN របស់អ្នកចូរកុំសាកស្មានលេខ PIN របស់អ អ្នកចុចវានៅកន្ទែង POS ម៉ាស៊ីនឬម៉ាស៊ីន ATM ។
បើសិនជាអ្នកចុចលេខ PIN របស់អ្នកខុសអ្នកមានចំនួនបីដងសំរាប់ចុចលេខដែលត្រូវ ។ បើសិនជាលេខ PIN ដែលត្រូវពិតមិនបានចុចសាកសលើកទីបួនទេ អ្នកមិនអាចនឹងប្រើប័ណ្ណរបស់អ្នកបានទៀតទេ រហូតទាល់តែក្រោយពេលពាក់ កណ្តាលអាធ្រាត ពីព្រោះម៉ាស៊ីនយាត់លេខប័ណ្ណរបស់អ្នកទុក ។ ក្នុងករណីខ្ញុះប័ណ្ណរបស់អ្នកត្រូវម៉ាស៊ីន ATM ស្រូបទុក ។ បើសិនជាម៉ាស៊ីន ATM ស្រូបប័ណ្ណរបស់អ្នកទុកចូរទាក់ទងទៅផ្នែកសេវាបំរើអ្ន្ស ឬអញ្ជើញទៅការិយាល័យ DSHS ក្នុងតំបន់
របស់អ្នកសំរាប់ការធ្វើប័ណ្ណជំនួស ។

តើខ្ញុំគួរធ្វើដូចម្តេច បើសិនជាជនណាម្នាក់ដឹងពីលេខ PIN របស់ខ្ញុំ?

ខ្ញុំត្រូវតែជ្រើសយកលេខ PIN ថ្មីដាបន្ទាន់ដោយទូរស័ព្ទទៅផ្នែកសេវាបំរើអ្ន្ស ឬដោយប្តូរលេខ PIN តាមបណ្តាញអ៊ីនធើណេតនៅ
www.ebtaccount.jpmorgan.com ។